ឧបសោសង្ហា

# ប្រតិបត្តិការសឹក កំពង់ចាម



GENERAL SOSTHENE FERNANDEZ (AU MILIEU)

## ពិនិត្យឡើងវិញនូវព្រឹត្តិការណ៏សំខាន់ៗមាននៅក្នុងប្រវត្តិសាស្រ្តខ្មែរ

### មាតិការឿង


បរិបទ នយោបាយ និង យោធា ........................ 2
សមរភូមិ ........................................................................ 5
អំពី ផែនការសឹក ........................................................ 7
អត្ថាធិប្បាយ ................................................................ 10

ប្រតិបត្តិការសឹក កំពង់ចាម[1] ជា ប្រតិបត្តិការសឹកវៃលុកខ្លាំងមួយសំខាន់ ហើយ កងទ័ពជាតិខ្មែរទទួលបានជ័យជំនះលើសមរភូមិ។

ក្នុងអំឡុងឆ្នាំ ១៩៧០-១៩៧៣, ពួកខ្មែរក្រហម ឬ រណសិរ្សបង្រួបបង្រួមជាតិខ្មែរ (FUNK) ពុំមានសកម្មភាពសឹកធំដុំអ្វីឡើយ នៅលើសមរភូមិ ព្រោះ ពួកយួនកុម្មុយនិស្ត ដែលជាចៅហ្វាយ គេយល់ឃើញថា ពួកខ្មែរក្រហម មិនទាន់រៀបចំរួចរាល់នៅឡើយ។ ក្នុងរយៈពេលនោះ ពួកខ្មែរក្រហម ប្រមូលកម្លាំង ដើម្បី រៀបចំ មូលដ្ឋានសឹក នៅក្នុងដំបន់ ដែលពួកយៀកកុងកាន់កាប់។ ចំនួន យោធាមានប្រមាណ ៤០.០០០ នាក់។ បន្ទាប់ពី សហរដ្ឋអាមេរិក និង យួនខាងជើង ចុះហត្ថលេខា នៃ កិច្ចព្រមព្រៀងសន្តិភាព នៅថ្ងៃទី២៧ កុម្ភៈ ឆ្នាំ ១៩៧៣, ពួកយួនកុម្មុយនិស្ត តម្រូវឲពួកខ្មែរក្រហម ធ្វើសកម្មភាពយោធា លើសមរភូមិ

---

[1] ដកស្រង់ពីឯកសារពីរជាកំណត់ការចងចាំ: Mémoires d'une guerre oubliée par le Lieutenant Général Sosthène Fernandez, ancien Commandant en Chef et Chef d'Etat-Major Général de l'Armée nationale khmère - Edition AsieInfo របស់ឧត្តសេនីយឯក សុស្ថែន ហ្វែរណង់ដេស និង The khmer Republic at War and the Final Collapse - U.S. ARMY OF MILITARY HISTORY, របស់ឧត្តមសេនីយឯក សាក់ សុតសាខន។ អត្ថបទទាំងពីរសរសេរជាភាសាបរទេស។ ខ្ញុំមិនយកមកបកប្រែជាភាសាខ្មែរនោះទេ គឺគ្រាន់តែយកគោលគំនិតតែប៉ុណ្ណោះ។

*(note de bas de page - suite)*

ដើម្បី ពួនលាក់កងទ័ពខ្លួន ក្នុងជួរពួកខ្មែរក្រហម។ សកម្មភាពធំ គឺ វៃកាត់ផ្តាច់ផ្លូវទឹក ទន្លេមេកុង និង ផ្លូវជាតិ លេខ៣[2] ដែលជាច្រករបៀង (corridor) ដឹកស្បៀងសំរាប់ចិញ្ចឹមជីវិត ប្រជាជន រស់នៅទីក្រុងភ្នំពេញ។ សមរភូមិនោះ ជាឆន្ទះរបស់ យួនកុម្មុយនិស្ត ហើយដើម្បី ជួយពួកខ្មែរក្រហម គេ ធ្វើសម្ពាធ គ្រប់សមរភូមិ ដើម្បី កុំឲកងទ័ពជាតិខ្មែរ ដកទៅជួយ ការវៃលុកនោះ។ យុទ្ធសាស្ត្រយួនកុម្មុនិស្ត ថ្មីនេះ គឺចង់បង្ហាញ ដល់ មតិអន្តរជាតិថាសង្គ្រាមនៅស្រុកខ្មែរ ជា សង្គ្រាមស៊ីវិល រវាង ខ្មែរនិងខ្មែរហើយកងទ័ពយួន បានដកចេញពីកម្ពុជា ស្របតាម កិច្ចព្រមព្រៀងសន្តិភាព។ ដើម្បី ឲយុទ្ធសាស្ត្រ ប្តូរពីសង្គ្រាមឈ្លានពាន ទៅជា សង្គ្រាមស៊ីវិល ឲមាន កំទរខ្លាំង, នៅថ្ងៃទី ១៧ មីនា ឆ្នាំ ១៩៧៣ វេលាម៉ោង ៤ល្ងាច, កូនប្រសារបស់សម្តេច សីហនុ, អនុសេនីយទោ ឈ្មោះ សៅ ផូត្រា, អ្នកបើកយន្តហោះ T28 បានទំលាក់គ្រាប់បែក ២គ្រាប់លើវិមានប្រធានាធិបតី ចំការមន។ តែ មិនប៉ះពាល់ដល់សវត្ថិភាព លោក លន់ នល់ នោះទេ។ ក៏ប៉ុន្តែ បន្ទាយ កងអង្គរក្ស របស់លោក ត្រូវឆេះខ្ទេចអស់។ នៅពេលនោះលោក ហង់ ធុនហាក់ ជា រដ្ឋមន្ត្រីទី១ បានស្នើដល់រដ្ឋសភាជាតិ ចាត់វិធានការ ខ្លាំងចំពោះ រាជវង្សានុវង្ស គឺថា បញ្ជូនទៅតុលាការ ដើម្បីកាត់ទោស ពីបទ ធ្វើសហការ

2 ផ្លូវជាតិលេខ៣ : ភ្នំពេញ-តាកែវ-កំពត។

ជាមួយសត្រូវ, តែរដ្ឋសភា បដិសេធនឹង សំណើរនោះ ដែលនាំឲលោកលាលែងពីដំណែង។ លោក លន់ នល់ ស្នើ ដល់លោក ឱប គីម អាង, ពេលនោះជា អគ្គលេខាធិការ គណបក្ស សាធារណរដ្ឋ, ឲរៀបចំរដ្ឋាភិបាលថ្មី តែ លោក បានបដិសេធ ព្រោះ គណបក្សសាធារណរដ្ឋ មានទំនាស់នយោបាយ ជាមួយលោក លន់ នល់ ស្ដីពី សេចក្ដីប្រកាសជាឯកតោភាគី នូវអនុក្រឹតឈប់បាញ់គ្នា ជាមួយពួកខ្មែរក្រហម[3]។ នៅចំពោះមុខ ការបដិសេធ នោះ, លោក លន់ នល់ ក៏បានស្នើ ដល់ លោក អ៊ីន តាំ ឲរៀបចំ រដ្ឋាភិបាលថ្មី។ លោក អ៊ីន តាំ សុខចិត្ត តែមានលក្ខខណ្ឌ[4] : រដ្ឋាភិបាល របស់លោក គឺជា រដ្ឋាភិបាល ‹ការផ្សះផ្សាជាតិ› គឺថា លោក សាកល្បង រកទំនាក់ទំនងផ្ទាល់ជាមួយ សម្ដេច សីហនុ ដើម្បី ដោះស្រាយ បញ្ហា សង្គ្រាម តាមសន្តិវិធី។ លោក លន់ នល់ យល់ព្រមតាមលក្ខខណ្ឌ របស់លោក អ៊ីន តាំ។ នៅថ្ងៃទី ១០ ឧសភា លោក អ៊ីន តាំ បានដោះលែងកូន ៥នាក់ និង សហការីជំនិត ៤នាក់ របស់សម្ដេច សីហនុ ហើយ អនុញ្ញាតឲ អ្នកទាំងនោះ អាចចាកចេញពីកម្ពុជាបាន។ ទង្វើនេះ ជាវិធានការ សំរាប់ស្វែងរកការចរចា

[3] ពួកខ្មែរក្រហាម ច្រានចោល កិច្ចព្រមព្រៀងការសន្តិភាព ឆ្នាំ ១៩៧៣។

[4] លោក ចៅ សៅ ដែលជា អគ្គលេខាធិការ គណបក្សប្រជាធិបតេយ្យ ដឹកនាំដោយលោក អ៊ីន តាំ បដិសេធ ចូលរួមក្នុង រដ្ឋាភិបាលថ្មី ដឹកនាំដោយប្រធានបក្សលោក ដ្បិតគាត់គ្មានជំនឿលើកការចរចានោះឡើយ ព្រោះគាត់យលឃើញថា រណសិរ្ស បង្រួបបង្រួមជាតិ (ពួកខ្មែរក្រហម) នឹងមានជ័យជំនះយោធា លើរបបសាធារណរដ្ឋខ្មែរ។

ជាមួយ សម្តេច សីហនុ នៅក្នុង ក្របខណ្ឌកិច្ចព្រមព្រៀង សន្តិភាព ដែលខ្មែរក្រហម បានបដិសេធ។

## សមរភូមិ

តែលើ សមរភូមិ នៅឆ្នាំ ១៩៧៣ នៅរដូវខែប្រាំង ពួកខ្មែរក្រហម បានដកទ័ពចេញពី សមរភូមិ ទន្លេមេគុង។ ការដកនោះ អាចឲ កងពលធំ (division) លេខ២៣ នៃកងទ័ពជាតិ វៃចូលកាន់កាប់វិញបាន ដំបន់ខាងជើង នៃស្រុកព្រែកថ្មោត ហើយ កងពលធំ លេខ១ បើផ្លូវជាតិលេខ១ ខាងត្បូង ស្រុកអ្នកលឿងបាន។ នៅពេលជាមួយគ្នានោះ កងទ័ព យៀកកុង និង យួនខាងជើង ធ្វើសម្ពាធយ៉ាងខ្លាំង តាមផ្លូវជាតិលេខ២៦[5] និង លេខ២៧[6] និង ទីក្រុងកំពង់ចាម។ កងទ័ពយួនកុម្មុយនិស្ត វៃយកបានស្រុកជាច្រើន គឺ តាំងគោក, ស្គុន, ព្រៃទទឹង និង ទ្រៀង។ នៅថ្ងៃទី១៦ សីហា ទីក្រុងកំពង់ចាម ត្រូវបានទ័ពរួម ខ្មែរក្រហម-យួនកុម្មុយនិស្ត វៃចូលបាន ពាក់កណ្តាលក្រុង។ ដើម្បីរំដោះ កងទ័ពជាតិខ្មែរ បានបញ្ជូន កងពលតូច (brigarde) លេខ២៧៩, ២កងវរសេនាតូច (bataillon) ឆ័ត្រយោង, ២កងវរសេនាតូច នៃកងពលតូច លេខ២៥ និង ៤

[5] ផ្លូវជាតិ លេខ២៦ : ព្រែកក្តាម-ស្គន់-កំពង់ធំ-សៀមរាប-ស៊ីសូផុន។
[6] ផ្លូវជាតិ លេខ២៧ : ស្គន់-កំពង់ចាម-ក្រែក-មេមត់-ស្នួល។

កាំភ្លើងធំ ១០៥ មម។ នៅថ្ងៃទី១ កញ្ញា កងទ័ពជាតិខ្មែរ វៃបែកខ្សែក្រវាត់ការពារ របស់ខ្មាំង ហើយ រុលចូលបាន ចម្ងាយ ១ គម ទៅក្នុងក្រុង តែខ្មាំង ទប់ទល់យ៉ាងខ្លាំង នូវការរុលចូលនោះ។ ក្នុងស្ថានភាពនោះ អគ្គបញ្ជាការ កងទ័ពជាតិខ្មែរ តម្រូវ បន្ថែម កងវរសេនាតូច នៃកងពលតូច លេខ៥ និង កងពលតូចឆ័ត្រយោង ១កងទៀត និង ២កងឯកភាពពិសេស (Task Force Alpha[7]) តាមផ្លូវទឹក ដើម្បី រក្សាទីតាំងដែលវៃយកបានពីខ្មាំង។ នៅក្នុងទីក្រុងកំពង់ចាម ខ្មាំង ព័ទ្ធ ទីបញ្ជាការទ័ពខ្មែរ មានចម្ងាយតែ ពីរបីម៉ែត្រ តែប៉ុណ្ណោះ។ ក្នុងស្ថានការបែបនេះ ឧត្តមសេនីទោ ស ហោ, មេបញ្ជាការសឹក, បានសុំឲយន្តហោះ នៃទ័ពអាកាសខ្មែរ ទំលាក់គ្រាប់បែកលើទីតាំងខ្មាំង ដែលគេទុកជា វិធានការ អត្តឃាតតកម្ម។ តែដោយសារ ការប្រសប់ នៃអ្នកបើកយន្តហោះខ្មែរ ទីតាំងខ្មាំង ត្រូវបាន ទំលាក់ត្រូវ នាំឲពួកគេដកថយ រកកន្លែងពួន។ នៅថ្ងៃទី៧ កញ្ញា, ២កងវរសេនាតូឆ័ត្រយោងជំនួយបានមកដល់សមរភូមិ តាម ១៦នាវា ដឹកទ័ព នៃកងទ័ពជើងទឹកជាតិខ្មែរ វៃចូល ក្នុងទីក្រុង ហើយបើកបានប្រហោងកំពែងខ្មាំង ហើយនៅថ្ងៃទី១០, កងពលតូច

[7] Task Force Alpha ជាកងកម្លាំង នៃខ្មែរកម្ពុជាក្រោម នៅក្រោមបញ្ជាការ របស់កងទ័ពអាមេរិកាំង។ កងពិសេសនេះ អាមេរិកាំង បញ្ជូនមកជួយច្បាំង នៅស្រុកខ្មែរ នៅចុងឆ្នាំ ១៩៧០ មានចំនួនប្រមាណ ៤.០០០ នាក់ បែងចែកជា កងវរសេនាធំ (régiment)។

លេខ៨០ វែពីក្រោយទ័ពខ្មាំង ពីទិសខាងត្បូង រុលចូលស ន្សឹមៗ ទៅក្នុងទីក្រុង រហូតដល់ថ្ងៃទី១៤ បាន ផ្គោបជួប នឹង កងយោភូមិទីក្រុង ហើយនាំគ្នា វៃយកទីតាំងខ្មាំង នៅមហាវិទ្យាល័យកំពង់ចាមបាន។ ហើយចាប់ពីថ្ងៃទី១៤ ទីតាំងខ្មាំងទាំងឡាយ បានធ្លាក់ម្ដងមួយៗ ដូចយ៉ាង ភូមិអង្គរក្នុង, បឹងកក់ និង រោងចក្រធ្វើក្រណាត់។ ចំពោះ ឧត្ដមសេនីយ សាក់ សុតសាខន លោក ចាត់ទុក សមរ ភូមិកំពង់ចាម ជាជោជ័យ របស់កងទ័ពជាតិខ្មែរ។ គឺជា ប្រតិបត្តិការសឹកចម្រុះ រវាង កងទ័ព ជើងគោក ជើងទឹក និង ជើងអាកាសខ្មែរ។

## អំពី ផែនការសឹក

ផែនការសឹក គឺ ឧត្ដមសេនីយឯក សុស្ដែន ហ្វែរណង់ដេស ជាអ្នករៀបចំ ក្នុងឋានៈលោក ជាអគ្គមេបញ្ជាការ និង អគ្គនាយសេនាធិការ នៃកងយោពលខេមរជាតិ។

**ទីតាំងខ្មាំង**

ត្រើយខាងកើតនៃទន្លេបិត ជាទីតាំងយៀកកុង កាន់ កាប់ ហើយពីទីនោះ ខ្មាំងតាំងកាំភ្លើងធំ បាច់ចូលមក ក្នុងទីក្រុងកំពង់ចាម ហើយទីក្រុងនេះ ត្រូវបានខ្មាំង ចូលកាន់កាប់បាន ពាក់កណ្ដាលស្រេច។ មិនតែប៉ុណ្ណោះ

ខ្មាំង កាន់កាប់ វាលយន្តហោះ និង ស្រុក ពាមជីកង ដែលស្ថិតនៅតាមដងទន្លេមេកុង ចម្ងាយ ១៥ គ.ម. ពីទីក្រុងកំពង់ចាម។

## ផែនការសឹក

ជាប្រតិបត្តិការសឹក ចម្រុះ រវាង កងទ័ព ជើងគោក, ជើងទឹក និង ជើងអាកាសខ្មែរ ដែលខ្មាំងមិនអាចនឹកស្មានថា កងទ័ពជាតិខ្មែរអាចធ្វើបាន។ តាមផ្លូវទឹកពី ភ្នំពេញទៅ ទន្លេបិត ខ្មាំង តាំងនៅត្រើយខាងឆ្វេងទន្លេ នូវអាវុធធុនធ្ងន់ជាច្រើន សំរាប់បាញ់នាវា ហើយខ្មាំងបាញ់លិចនាវាច្រើនគ្រឿង។ ទីតាំងនោះ គឺសំរាប់ បិទផ្លូវមិនឲកងទ័ពជើងទឹក ដឹកជញ្ជូនទ័ព ទៅកាន់ ទីក្រុងកំពង់ចាមបាន។ ដូច្នេះ ជាបឋម ត្រូវចាំបាច់ឲ កងទ័ពអាកាសកំទិចទីតាំងទាំងនោះឲបាន។ តាម ការឈ្លបយកការដោយយន្តហោះ គេឃើញខ្មាំងមាន ទីតាំងកាំភ្លើងធំ ពីស្រុក ពាមជីកង រហូតដល់ទីក្រុងកំពង់ចាម។ ដើម្បីជៀសវៀង ការវាយប្រហារ របស់ខ្មាំងតាមផ្លូវ ដែលវារៀបចំទុកជាមុន ដោយវានឹងស្មានថា ទ័ពខ្មែរ ច្បាស់ជាដឹកទ័ពតាមនាវា មកចុះនៅស្រុកពាមជីកង តែ ឧត្តមសេនីយសុស្តែន ហ្វែរណង់ដេស បានប្តូរ ផ្លូវដឹកជញ្ជូនទ័ព គឺថា ២ កងពលតូច នៃទ័ពជាតិខ្មែរ ដែរគ្រោងទុកថា ត្រូវ ជញ្ជូនតាមផ្លូវទឹក បែរជាចុះពីនាវា មុនដល់ ស្រុកពាមជីកង

ហើយដើរឆ្ពោះទៅទីក្រុងកំពង់ចាម តាមផ្លូវជាតិទៅវិញ។ ហើយ ២កងពលតូចទៀត ផ្តោតវៃ វាលយន្តហោះ កាន់កាប់ដោយខ្មាំង ដើម្បី នឹងអាចដឹកជញ្ជូនកងទ័ពតាមផ្លូវអាកាស នៅពេលណា ដែលត្រូវការ ជាចាំបាច់។ កលល្បិចនេះ ខ្មាំងមិននឹកស្មានសោះដែរ។ តែពេល ជាមួយគ្នានោះដែរ ទីតាំងខ្មាំង នៅតាមច្រាំងទន្លេ ត្រូវបាន ឧទ្ទម្ភាគចក្រ នៃទ័ពអាកាសខ្មែរ បាញ់រះ និង កាំភ្លើងធំ នៃកងទ័ពជើងទឹកខ្មែរ បាច់ផ្លោង ដើម្បីកំទិចចោល ដែលនាំឲខ្មាំងរឹតតែគិតថា ផ្លូវទឹក ជាផ្លូវជញ្ជូនទ័ពជំនួយ ទៅកាន់ក្រុងកំពុងចាម។ ការវៃប្រហារនោះ បង្ខំខ្មាំងឲនៅស្ងៀមមួយកន្លែងអស់មួយរយ: ហើយ ឥតបានដឹកថាមាន ២កងពលតូច នៃកងទ័ពជាតិខ្មែរ កំពុងតែដើរឆ្ពោះ ទៅរកទីក្រុងកំពង់ចាមនោះឡើយ។ ផែនការនោះគឺ ធ្វើឲខ្មាំង មានការភ្ញាក់ផ្អើល ដោយសារ ភាពរហ័ស នៃចរភាព នៃកងប្រយុទ្ធ ហើយនិង យុទ្ធសាស្ត្រឆ្លើយតបនឹងខ្មាំង ដែលខ្មាំង មិននឹកស្មានបាន ព្រោះមិនអាចកំណត់បានថា តើទីកន្លែងណាពិតប្រាកដ ដែលទុកជាការវាយប្រហារធំ របស់កងទ័ពជាតិខ្មែរ។

យុទ្ធសាស្ត្រនេះ ធ្លាប់កងទ័ព រ៉ូស៊្សី ប្រើដំបូង នៅពេលសង្គ្រាម លោកលើកទី១ ហើយគ្រប់សាលា យុទ្ធសាស្ត្រយោធាធំៗ គេយកមកបង្រៀន ដល់នាយទាហ៊ានជាន់ខ្ពស់។ គឺ

វៃគ្រប់ ទីតាំងខ្មាំង ក្នុងពេលតែមួយ ដើម្បី កុំឲខ្មាំងដឹងថា តើទីកន្លែងណាពិត ដែលជាចំណុចវៃធំ។

## អត្ថាធិប្បាយ

ជ័យជំនះ វាជាបញ្ហា នៃឆន្ទៈ។ ត្រូវដឹងថា ចាប់ពីថ្ងៃទី១៥ សីហា ឆ្នាំ ១៩៧៣ នៅក្នុងក្របខណ្ឌ នៃកិច្ចព្រមព្រៀងសន្តិភាព ២៧ កុម្ភៈ ឆ្នាំ ១៩៧៣, កងទ័ពអាកាស អាមេរិកាំង លែងអាចធ្វើអន្តរាគមន៍នៅស្រុកខ្មែរបានជាដាច់ខាត។ សហរដ្ឋអាមេរិក លែងផ្តល់ជំនួយយោធា និង ថែមទាំងកាត់ជំនួយសេដ្ឋកិច្ច។ វាហាក់បីដូចជា សហរដ្ឋអាមេរិក មិនចង់ខ្វះខ្វាយថវិការជាតិខ្លួន តែនៅលើសមរភូមិនៅកម្ពុជា យុទ្ធជនខ្មែរ ត្រូវបន្តចំណាយជីវិត ដើម្បីប្រឆាំងនឹងកម្លាំងកុម្មុយនិស្ត ដែលជាសត្រូវនឹង សហរដ្ឋអាមេរិក។ កិច្ចព្រមព្រៀងសន្តិភាព របស់អាមេរិកាំង គឺសំរាប់តែ ដកទ័ពអាមេរិកាំងចេញពីសមរភូមិ ប្តូរនឹងឈ្លើយសង្គ្រាម តែមិនអាច បង្ខំសត្រូវខ្លួន មិនឲបន្តវៃប្រហារ ទៅលើកងទ័ព ជាមិត្តរបស់ខ្លួន, មិនតែប៉ុណ្ណោះ គឺថែមទាំង ផ្តាច់ជំនួយសឹក មិន ឲកងទ័ព ធ្លាប់ស្ម័គ្រច្បាំងជាមួយខ្លួន គ្មានមធ្យោបាយ ការពារខ្លួន។ តាមពិត វាជាកិច្ចព្រមព្រៀងសន្តិភាព ចងដៃ កងទ័ពជាតិ ខ្មែរ និង ឃុនខាងត្បូង ទុកឲ កងទ័ពយៀកកុង និង ឃុនខាង

ជើង វៃតាមតែចិត្ត[8]។ គេមិននឹងគិតស្មានថា សហរដ្ឋអាមេរិក ទោះបី ធ្វើយ៉ាងណា មិនឲខ្លួនបាក់មុខមាត់ ជាអ្នកចាញ់សង្រ្គាម ក្នុងការដកខ្លួន ចេញពីយៀកណាម, ហើយដោយសារខ្លួនគិតតែ អំពី កិត្យានុភាពនោះ ទោះបីមិនបានយកចិត្តទុកដាក់ អំពី សីលធម៌ និង មនុស្សធម៌ ក៏គួរធ្វើយ៉ាងណា កុំអោយ ការបញ្ចប់សង្រ្គាម វានាំមក នូវសោលនាដកម្ម ដល់ប្រជាពលរដ្ឋខ្មែរ ដែលមាន ការទុកចិត្តទៅលើខ្លួន ក្នុងឋានៈជាមហាអំណាច នៃលោកសេរី និង មហានគរ នៃលទ្ធិប្រជាធិបតេយ្យ។ លិខិតរបស់ទ្រង់ ស៊ីសុវត្ថ សិរិមតៈ ឆ្លើយបដិសេធ តបនឹងការអញ្ជើញរបស់លោក ឯកអគ្គរដ្ឋទូត នៃសហរដ្ឋអាមេរិក លោក Jonh Gunther Dean ស្នើសុំឲទ្រង់ ចាកចេញពីស្រុកកំណើត ដោយសារអាមេរិកាំង បោះបង់ស្រុកខ្មែរ បង្ហាញឲឃើញថា ចម្លើយនោះ ជាសញ្ញាល័ក្ខ នៃការខកចិត្ត របស់ប្រជាពលរដ្ឋ ចំពោះ មហានគរ អាមេរិកាំង។ មួយឆ្នាំក្រោយពី ស្រុកខ្មែរ ធ្លាក់ចូលក្នុងទ្រុងខ្មោច នៃពួកខ្មែរក្រហម សពលោក ប្រធានាធិបតេយ្យ បារាំង François Mitterrand បានសរសេរនៅក្នុងប្លុក ប្រចាំសប្ដាហ៍ របស់គណបក្សសង្គមនិយមថា : ‹វាមិនមានលេស ជាការសុំ

[8] ប៉ុន្តែ កងទ័ពជាតិខ្មែរ នៅតែអាចបន្ត ប្រយុទ្ធ ជាមួយនឹងទឹកចិត្តទោះបីខ្វះសម្ភារៈ លើគ្រប់សមរភូមិ ដែលមាន វត្តមាន កងទ័ពកុម្មុយនិស្តយួនដដែល។ មិនតែប៉ុណ្ណោះ កងទ័ពយួនខាងជើង បានប្រើរថក្រោះ T54/55 នៅលើសមរភូមិខ្មែរ ព្រោះគេលែងខ្លាច ការវៃប្រហារ នៃយន្តហោះអាមេរិកាំង។

ទោសបានទោះឡើយ នៃការដួលរលំ នៃរដ្ឋជាទីខ្មែរ, ចំពោះរដ្ឋាភិបាល, ចំពោះ វិធីសាស្រ្ត នៃពួកខ្មែរក្រហម នៅស្រុកខ្មែរ (...)។ ដើម្បី បង្កើត នូវកតព្វកិច្ចអប់រំ, ដើម្បី បង្កើត នូវចិត្ត ទៅនឹងជម្រើស ដែលគិតស្មានថា ជាការ ប្តូរសង្គមទាំងអស់ មិនអាចប្រទ្បំ ដោយគ្មានការខូច ខាតធំ ជាមួយ ផលវិបាកគ្មានកំណត់ ជាមួយ គ្រឿង ម៉ាស៊ីន ដ៏គួរឲរន្ធត់នេះ ដែលបានបង្កើតឡើង សំរាប់ កម្ទេច សតិសម្បជញ្ញៈមនុស្ស តម្រូវតាម សេចក្តីត្រូវការ របស់សពាង្គ។ នៅភ្នំពេញ គឺវាមានកើតឡើងដូច្នេះឯង.›

សហរដ្ឋអាមេរិក អាចស្រែកថា ខ្លួនមានជ័យជំនះ នៃសន្តិភាព តែប្រជាពលរដ្ឋខ្មែរ ជាង២លាននាក់ ត្រូវបាត់បង់ជីវិត ក្នុងសន្តិភាព ដ៏រន្ធត់ ដែល អាមេរិកាំងចង់បាន នោះ។ ពិតប្រាកដណាស់ហើយថា សហរដ្ឋអាមេរិក ដាក់ កំហុសទៅលើ អសមត្ថកិច្ច នៃពួកដឹកនាំ របបសាធារណ រដ្ឋខ្មែរ និង កងយោពលខេមរជាតិ, តែជនខ្មែរ ដែលជា អ្នករងគ្រោះនឹងរបបខ្មែរក្រហម និង យួនកុម្មុយនិស្ត សួរ ថា តើលេសនេះ វាជាការពិតទាំងស្រុងដែរឬទេ ? អ្នកណា ជា អ្នកបំផ្លាចស្រុកខ្មែរសព្វថ្ងៃ ក្នុងនាមសន្តិភាព និង លទ្ធិប្រជាធិបតេយ្យ, តើមិនមែនពួកទាំងពីរនេះឬទេ ?